**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

លេខ .១២៦...អបស. មត

រាជធានីភ្នំពេញ ថ្ងៃទី .០៥...... ខែ កក្កដា ឆ្នាំ ២០០៥

# ប្រកាស
## ស្តីពី
## គំរូឯកសណ្ឋានថ្មីសំរាប់មន្ត្រីសុខាភិបាល

## រដ្ឋមន្ត្រីក្រសួងសុខាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស-រកត ០៧០៤១/១២៤ ចុះថ្ងៃទី១៥/០៧/២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/៩៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ-បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញរបាយការណ៍ប្រជុំពិភាក្សាស្តីពីឯកសណ្ឋានមន្ត្រីសុខាភិបាលលេខ ៣៥៦/០៤ អបស-មព ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០៤
- តាមការចាំបាច់របស់ក្រសួងសុខាភិបាល

## សំរេច
****

**ប្រការ១.-** ត្រូវបានអនុញ្ញាតអោយផ្លាស់ប្តូរឯកសណ្ឋានមន្ត្រីសុខាភិបាល ដែលកំពុងប្រតិបត្តិការក្នុងសេវាព្យាបាល និងថែទាំ ដើម្បីលើកកំពស់គុណភាពព្យាបាលថែទាំអោយមានប្រសិទ្ធិភាព និងមានតម្លាភាព ។

**ប្រការ២.-** ឯកសណ្ឋានប្រធាន — អនុប្រធានមន្ទីរពេទ្យ — ប្រធានផ្នែក ៖

- **អាវសដៃវែងត្រឹមជង្គង់**
- **កបើកដូចអាវធំ (Croisé)**
- **មានហោប៉ៅបញ្ឆិតពីរ**
- **ខាងក្រោយមានរែកនៅខាងក្រោមចំកណ្តាល**
- **ខោបារាំងពណ៌ស**
- **មួកពណ៌ស ។**

ប្រការ៣.- ឯកសណ្ឋានវេជ្ជបណ្ឌិតគ្រូពេទ្យមធ្យម :

- អាវសដៃវែងត្រឹមជង្គង់
- កបើកតូចធម្មតា
- មានហោប៉ៅបញ្ឆិត
- ខាងក្រោយមានផែកនៅខាងក្រោមចំកណ្ដាល
- ខោបារាំងពណ៌ស
- មួកពណ៌ស ។

ប្រការ៤.- ឯកសណ្ឋានឱសថការី និងទន្តបណ្ឌិត ទន្តពេទ្យ :

- អាវសដៃខ្លី —កតាំង បិតឡេវចំហៀង
- មានហោប៉ៅខាងស្ដាំ
- ខ្នងអាវ ប៉ានចង្កេះ ផែកកណ្ដាល
- ខោបារាំងពណ៌ស
- មួកពណ៌ស ។

ប្រការ៥.- ឯកសណ្ឋានគ្រូពេទ្យនៅផ្នែកសង្គ្រោះបន្ទាន់ ( ICU ) :

- អាវដៃខ្លីពណ៌ផ្ទៃមេឃសិកពីលើ
- កស្រួចមានហោប៉ៅបី
- ផែកចំហៀងសងខាង
- ខោដាក់កៅស៊ូពណ៌ផ្ទៃមេឃ
- មួកពណ៌ផ្ទៃមេឃ ។

ប្រការ៦.- ឯកសណ្ឋានគ្រូពេទ្យនៅផ្នែកប្លុកវះកាត់ :

- អាវប្លូដៃវែង ចងចង្កេះ ពណ៌បៃតងចាស់
- អាវដៃខ្លីពណ៌បៃតងចាស់ សិកពីលើ
- កស្រួចមានហោប៉ៅបី
- ផែកចំហៀងសងខាង
- ខោដាក់កៅស៊ូ ពណ៌បៃតងចាស់
- មួកពណ៌បៃតងចាស់ ។

ប្រការ៧.- ឯកសណ្ឋានគិលានុបដ្ឋាក-យិកា

- អាវដៃខ្លី កស្រួច ឡេវចំហៀង ពណ៌ស
- មានហោប៉ៅបី
- សំរុងអាវត្រឹមគូថ

-នៅចុងដៃអាវ និងលើហោប៉ៅមានចំក្រណាត់ឆ្នូត ពណ៌ខៀវចាស់-ស សំរាប់គិលានុបដ្ឋាកមធ្យម និង ពណ៌បៃតង-ស សំរាប់គិលានុបដ្ឋាកបឋម

-ខោដាក់កៅស៊ូ ពណ៌ស

-មួកពណ៌ស ។

ប្រការ៨.- ឯកសណ្ឋានឆ្មបនៅផ្នែកសម្ភព :

-អាវដៃខ្លី ពណ៌ស៊ីជំពូខ្ចី កស្រួច ឡេវចំហៀង

-មានហោប៉ៅបី

-សំរុងអាវត្រឹមគូថ

-នៅចុងដៃអាវ និងលើហោប៉ៅមានចំក្រណាត់ឆ្នូត ពណ៌ស៊ីជំពូខ្ចី-ស

-ខោដាក់កៅស៊ូ ពណ៌ស៊ីជំពូខ្ចី

-មួកពណ៌ស៊ីជំពូខ្ចី ។

ប្រការ៩.- ឯកសណ្ឋានមន្ត្រី បុគ្គលិកនៅផ្នែករដ្ឋបាល សាលាបច្ចេកទេសថែទាំវេជ្ជសាស្ត្រ សាលាមធ្យមសិក្សាសុខាភិបាលភូមិភាគ សកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល :

-អាវសដៃវែង កឌុប

-ខោបារាំងពណ៌ខៀវ ឬ សំពត់ពណ៌ខៀវ ។

ប្រការ១០.- អគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គាធិការដ្ឋាន មន្ទីរសុខាភិបាលខេត្ត-ក្រុង ព្រមទាំងមន្ត្រីសុខាភិបាលទាំងអស់ មានភារៈកិច្ចអនុវត្តតាមប្រកាសនេះអោយមានប្រសិទ្ធិភាពខ្ពស់ ។

ប្រការ១១.- រាល់លិខិតបទដ្ឋាន ឬ បទបញ្ញត្តិណា ដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ១២.- ប្រកាសនេះមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

វេជ្ជ. នុត-សុខុម

**ចំលងជូន:**

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងការងារ
-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
-អគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល
-អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ
-អគ្គាធិការដ្ឋានក្រសួងសុខាភិបាល
-មន្ទីរសុខាភិបាលខេត្ត-ក្រុង
-ឯកសារ-កាលប្បវត្តិ